# កិច្ចព្រមព្រៀង
# រវាង
# ក្រុមហ៊ុន ហ្វេមើសឡេតជឺវែរ (ខេមបូឌា) ឯ.ក
# និង តំណាងកម្មករនិយោជិក
# ស្តីអំពីការព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០២០ វេលាម៉ោង ១៥ និង៣០នាទីនៅក្នុងក្រុមហ៊ុន **ហ្វេមើស ឡេតជឺវែរ (ខេមបូឌា) ឯ.ក** មានកិច្ចប្រជុំរវាងតំណាងក្រុមហ៊ុន និងតំណាងកម្មករនិយោជិក។

នៅក្នុងអង្គប្រជុំនេះនាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិកទាំងអស់ អំពីស្ថានភាពបច្ចុប្បន្ននៅក្នុងរោងចក្រថា ដោយសារតែក្រុមហ៊ុនយើងខ្វះការបញ្ជាទិញដែលជាហេតុមិនអាចអោយសង្វាក់ផលិតកម្មរបស់រោងចក្រទាំងមូលដំណើរការបាន ហេតុដូចនេះ ក្រុមហ៊ុនសំរេចធ្វើការសុំព្យួរកិច្ចសន្យាការងាររបស់កម្មករ និយោជិកទាំងអស់ ១៣៧នាក់ ស្រី១១៥នាក់ រយៈពេលចំនួន ៣ សប្តាហ៍ ដោយគិតចាប់ពី ច័ន្ទ ថ្ងៃទី ១០ ខែសីហា ឆ្នាំ២០២០ រហូតដល់ ថ្ងៃច័ន្ទ ទី ៣១ ខែសីហា ឆ្នាំ ២០២០។

នៅក្នុងកំឡុងពេលនៃការព្យួរការងារនេះបានឯកភាពទទួលនូវការផ្តល់ជូនរបស់ក្រុមហ៊ុននូវប្រាក់ឈ្នួល ៣០ដុល្លាអាមេរិកក្នុង ១ខែ សំរាប់កម្មករនិយោជិកម្នាក់។

អង្គប្រជុំបានបញ្ចប់វេលាម៉ោង ១៦ គត់ នាថ្ងៃខែដដែល ដោយភាគីទាំងសងខាងមានភាពស្និតស្នាល និងការយោគយល់គ្នាក្រោមស្មារតីទទួល និងសហការគ្នាយ៉ាងរលូន។

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០

**តំណាងកម្មករនិយោជិក**

**ជ. នាយកក្រុមហ៊ុន**

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
ហ្វេមើស ឡេតជឺវែរ (ខេមបូឌា) ឯ.ក
FAMOUS LEATHERWARE(CAMBODIA)
CO.,LTD.
KINGDOM OF CAMBODIA